**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ១៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃ មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៩ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

Downloaded from http://www.khmerlaws.com

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណង**

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ។

**មាត្រា ២.- គោលដៅ**

អនុក្រឹត្យនេះ មានគោលដៅកំណត់ក្របខ័ណ្ឌគតិយុត្តសម្រាប់ផ្តល់ឥណទានរយៈពេលខ្លី មធ្យម និងវែង ដល់សមាគម សហគមន៍ ឬក្រុមហ៊ុន ដើម្បីជួយទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ។

**មាត្រា ៣.- វិសាលភាព**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ដែលជាកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់ឥណទានចំពោះសកម្មភាពជាអាទិភាពដូចតទៅ :

១-ផ្តល់ឥណទានរយៈពេលខ្លី ដល់សមាគម សហគមន៍ ឬក្រុមហ៊ុន សម្រាប់ការប្រមូលទិញស្រូវ-អង្ករ កសិផល និងអនុផលផ្សេងទៀតពីកសិករតាមតម្លៃមួយសមរម្យ ដើម្បីធានាស្ថិរភាពថ្លៃ និងសន្តិសុខស្បៀង ។

២-ផ្តល់ឥណទានរយៈពេលមធ្យម និងវែងដល់សមាគម សហគមន៍ ឬ ក្រុមហ៊ុនកែច្នៃស្រូវ-អង្ករ កសិផល និងអនុផលផ្សេងទៀត សម្រាប់ពង្រីកសមត្ថភាពឃ្លាំងស្តុក ម៉ាស៊ីនសម្ងួត និងម៉ាស៊ីនកែច្នៃទំនើប ដើម្បីពង្រឹងសមត្ថភាព និងគុណភាពកែច្នៃផលិតផលកសិកម្មដែលបម្រើសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញ ។

៣-ផ្តល់ឥណទានរយៈពេលមធ្យម និងវែងដល់សមាគម សហគមន៍ ឬ ក្រុមហ៊ុនក្នុងគោលដៅអភិវឌ្ឍអនុវិស័យផ្សេងៗ ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ។

**មាត្រា ៤.- និយមន័យ**

"សហគមន៍ ឬសមាគម" សំដៅដល់នីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន នៅស្ថាប័នមានសមត្ថកិច្ច និងធ្វើសកម្មភាពក្នុងវិស័យកសិកម្ម ឬកសិ-ឧស្សាហកម្ម ។

Downloaded from http://www.khmerlaws.com

"ក្រុមហ៊ុន" សំដៅដល់នីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅក្រសួងពាណិជ្ជកម្ម ហើយធ្វើសកម្មភាពចម្បង ឬសកម្មភាពគាំទ្រក្នុងវិស័យកសិកម្ម ឬ កសិ-ឧស្សាហកម្ម ដែលមានជាអាទិ៍ ផលិតកម្មដំណាំស្រូវ ដំណាំអនុផល ការកែច្នៃស្រូវ-អង្ករ និងអនុផលផ្សេងៗ ការចិញ្ចឹមសត្វ និងមច្ឆាវប្បកម្ម ។

"រយៈពេលខ្លី" សំដៅដល់រយៈពេលដែលមិនលើសពី ១ (មួយ)ឆ្នាំ ។

"រយៈពេលមធ្យម"សំដៅដល់រយៈពេលដែលលើសពី ១(មួយ) ឆ្នាំ និងមិនលើសពី ៣(បី) ឆ្នាំ ។

"រយៈពេលវែង" សំដៅដល់រយៈពេលដែលលើសពី ៣(បី) ឆ្នាំ ឡើងទៅ ។

## ជំពូកទី ២

## រចនាសម្ព័ន្ធគ្រប់គ្រង

### មាត្រា ៥.- ក្រុមប្រឹក្សាគោលនយោបាយ

មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតក្រុមប្រឹក្សាគោលនយោបាយមួយ ដែលមានតួនាទីកំណត់គោលនយោបាយក្នុងការប្រើប្រាស់ឥណទានសម្រាប់ជួយទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

សមាសភាពក្រុមប្រឹក្សាគោលនយោបាយមានដូចខាងក្រោម :

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អនុប្រធាន |
| ៣-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥-តំណាងវិស័យឯកជនក្នុងវិស័យកសិកម្ម | សមាជិក |
| ៦-ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | លេខាធិការ |

ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាគោលនយោបាយ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រធានក្រុមប្រឹក្សាគោលនយោបាយ មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័នផ្សេង

Downloaded from http://www.khmerlaws.com

ទៀតចូលរួមពិភាក្សាការងារតាមការចាំបាច់ ។

**មាត្រា ៦.- គណៈកម្មការឥណទាន**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មការឥណទានមួយ ដើម្បីអនុវត្តគោលនយោបាយកំណត់ដោយក្រុមប្រឹក្សាគោលនយោបាយ ។ គណៈកម្មការឥណទាននេះមានភារកិច្ចវាយតម្លៃ អនុម័តគម្រោង និងត្រួតពិនិត្យការអនុវត្តគម្រោងឥណទាន ក្នុងក្របខណ្ឌមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ។

គណៈកម្មការឥណទាន ត្រូវលើកសំណើសុំផ្តល់ឥណទានដល់គម្រោង ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច។

គណៈកម្មការឥណទានមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- | ប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ | ជាប្រធាន |
| ២- | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | តំណាងធនាគារអភិវឌ្ឍជនបទ ០២ រូប | សមាជិក |
| ៤- | មន្ត្រីជំនាញនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ០១ រូប | សមាជិក ។ |

ការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈកម្មការឥណទាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នីតិវិធីនៃការស្នើសុំ និងអនុម័តផ្តល់ឥណទាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៧.- ស្ថាប័នអនុវត្ត**

ធនាគារអភិវឌ្ឍន៍ជនបទ គឺជាស្ថាប័នគ្រប់គ្រងការអនុវត្តគម្រោងឥណទាន ដែលត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៨.- ការរៀបចំរបាយការណ៍**

ធនាគារអភិវឌ្ឍន៍ជនបទ និងគណៈកម្មការឥណទាន ត្រូវធ្វើរបាយការណ៍នៃការប្រើប្រាស់ឥណទានជាទៀងទាត់ និងតាមការចាំបាច់ ជូនក្រុមប្រឹក្សាគោលនយោបាយ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរាយការណ៍តាមការចាំបាច់ ជូនរាជរដ្ឋាភិបាល អំពីការប្រើប្រាស់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ។

Downloaded from http://www.khmerlaws.com

## ជំពូកទី ៣

## ប្រភពធនធាន និងការប្រាក់

**មាត្រា ៩.- ប្រភពធនធាន**

ប្រភពធនធាននៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម រួមមាន ៖

- ធនធានដំបូងជាឥណទានពិសេសចំនួន ៧២,០០០,០០០,០០០៛ (ចិតសិបពីរពាន់លានរៀល) ដែលកំណត់ដោយច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- ធនធានបន្ថែមពីប្រភពថវិកាជាតិ ទៅតាមការចាំបាច់របស់រាជរដ្ឋាភិបាល
- ការចូលរួមវិភាគទានពីដៃគូអភិវឌ្ឍន៍ និង
- ប្រភពផ្សេងទៀត ។

**មាត្រា ១០.- ការប្រាក់**

ការផ្តល់ឥណទាន ត្រូវកំណត់អត្រាការប្រាក់មិនខ្ពស់ជាងអត្រាការប្រាក់របស់ធនាគារពាណិជ្ជនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អត្រាការប្រាក់នៃឥណទាននេះត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការប្រាក់ដែលទទួលបានមកពីការផ្តល់ហិរញ្ញប្បទាននេះ ត្រូវយកទៅប្រើប្រាស់សម្រាប់ការគ្រប់គ្រងប្រតិបត្តិការនៃការផ្តល់ឥណទាន និងការបង្កើនមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## ទោសប្បញ្ញត្តិ

**មាត្រា ១១.- ទោសប្បញ្ញត្តិ**

មន្ត្រីសាធារណៈទាំងឡាយណា ដែលត្រូវបានរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ដោយការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនចំពោះការគ្រប់គ្រង ឬការប្រើប្រាស់មូលនិធិក្នុងស្ថានភាពមិនសមស្រប និងធ្វើឱ្យបាត់បង់ដោយប្រការណាមួយតាមរយៈការលួចកិបកេង ក្លែងបន្លំ ឬ ប្រើប្រាស់មូលនិធិនេះខុសគោលដៅ ត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានដោយមិនទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។

Downloaded from http://www.khmerlaws.com

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១២.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ប្រធាន គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១៣ "ដើម្បីអនុវត្ត"
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com